**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ១៨ ស.រ.ល១**

# សារលិខិត

## សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
## ផ្ញើជូនជនរួមជាតិកម្ពុជា
## ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

**- សូមក្រាបបង្គំទូលថ្វាយព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្ដីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត**

**- សម្ដេចព្រះមហាសង្ឃរាជ សម្ដេចព្រះសង្ឃនាយក សម្ដេចព្រះរាជាគណៈ ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់**

**- សម្ដេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី ជាទីមេត្រី**

**- បងប្អូនជនរួមជាតិ ដែលកំពុងរស់នៅក្នុងនិងក្រៅប្រទេស ជាទីស្នេហា!**

ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំ សូមចូលរួមអបអរសាទរក្នុងពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ដែលប្រព្រឹត្តទៅនៅថ្ងៃសៅរ៍ ៥កើត ថ្ងៃអាទិត្យ ៦កើត ថ្ងៃចន្ទ ៧កើត និងថ្ងៃអង្គារ ៨កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៣ ទី១៤ ទី១៥ និងទី១៦ ខែមេសា ឆ្នាំ២០២៤ ជាមួយបងប្អូនជនរួមជាតិទាំងអស់ដែលកំពុងរស់នៅក្នុងនិងក្រៅប្រទេស ប្រកបដោយក្ដីសោមនស្សរីករាយ សិរីសួស្ដី និងជ័យមង្គលដ៏ឧត្តុង្គឧត្ដមក្នុងក្រុមគ្រួសារនិងសង្គមជាតិទាំងមូល។

ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ឆ្នាំនេះ ជាឆ្នាំដំបូងនៃអាណត្តិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា ដែលបានដាក់ចេញនូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ កាលពីខែសីហា ឆ្នាំ២០២៣ ជាពិសេស ការអនុវត្តនូវកម្មវិធីនយោបាយជាអាទិភាពសំខាន់ៗ និងវិធានការគន្លឹះក្នុងការកែទម្រង់ជាក់ស្ដែងនានា ដែលត្រូវបានដាក់ចេញឱ្យអនុវត្តជាបន្តបន្ទាប់ ចាប់ពីដើមនីតិកាលទី៧នៃរដ្ឋសភា ឱ្យសម្រេចបាននូវលទ្ធផលផ្លែផ្កាជាអតិបរមា ដើម្បីឆ្លើយតបទៅនឹងសំណូមពរ សេចក្ដីត្រូវការ និងការរំពឹងទុករបស់ប្រជាជនកម្ពុជាដែលជាម្ចាស់ឆ្នោត នៅក្នុងដំណាក់កាលថ្មីនៃការអភិវឌ្ឍ និងការរីកដុះដាលនូវសមិទ្ធផលធំៗថ្មីៗយ៉ាងច្រើនប្រកបដោយមោទនភាព។

រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា ដែលបានប្រសូតចេញពីការបោះឆ្នោតដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាព ស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងបានទទួលការគាំទ្រនិងជំនឿទុកចិត្តពីប្រជាពលរដ្ឋដ៏ច្រើនលើសលប់ កំពុងបន្តបេសកកម្មដ៏ឧត្តុង្គឧត្ដមជាប្រវត្តិសាស្ត្ររបស់ខ្លួនពីរាជរដ្ឋាភិបាល នីតិកាលទី៦នៃរដ្ឋសភា ជាមួយនឹងការប្ដេជ្ញាចិត្តយ៉ាងមុតមាំឥតរាថយនិងកាន់តែស្វាហាប់

ក្នុងការបម្រើប្រជាជន ក៏ដូចជាក្នុងការពន្លឿនកិច្ចអភិវឌ្ឍសង្គម សេដ្ឋកិច្ច ឆ្ពោះទៅរកអនាគតមួយដ៏រុងរឿង ស្របតាមឆន្ទៈនិងបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ប្រជាជន។

ឆ្នាំចាស់ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ បានកន្លងផុតទៅ ដោយជំនួសមកវិញនូវឆ្នាំថ្មី ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា ដែលបន្តពីរាជរដ្ឋាភិបាល នីតិកាលទី៦នៃរដ្ឋសភា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី បច្ចុប្បន្នជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងជាប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា** បានបន្តបេសកកម្មក្នុងឆន្ទៈដ៏មោះមុតបំផុត ក្នុងការបន្តកសាងប្រទេសជាតិឱ្យមានវឌ្ឍនភាពលើគ្រប់វិស័យ និងការពាររបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ឱ្យស្ថិតស្ថេរជានិរន្តរ៍។

ក្នុងឆ្នាំ២០២៣កន្លងទៅ និងរហូតដល់ដំណាច់ត្រីមាសទី១ ឆ្នាំ២០២៤នេះ កម្ពុជាក៏ដូចបណ្តាប្រទេសនៅលើពិភពលោកទាំងមូល ស្ថិតក្នុងស្ថានភាពមិនប្រាកដប្រជា ពោរពេញដោយភាពចម្រូងចម្រាស់ ការប្រកួតប្រជែងភូមិសាស្ត្រនយោបាយរវាងប្រទេសមហាអំណាចធំៗកាន់តែតានតឹង ដែលបង្កើតបានជាអធិករណ៍ប្រកបដោយហានិភ័យ។ តែទោះជាយ៉ាងនេះក្តី កម្ពុជានៅតែរក្សាបាននូវសុខសន្តិភាព ឯករាជ្យ អធិបតេយ្យជាតិ បូរណភាពទឹកដី ធានាបាននូវស្ថិរភាពនយោបាយ សន្តិសុខសណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ប្រក្រតីភាពស្ថាប័នរដ្ឋ និងគ្រប់សកម្មភាពនៃជីវភាពសង្គម ឱ្យមានការរីកចម្រើនទៅមុខប្រកបដោយទំនុកចិត្ត។

សមិទ្ធផលដែលលេចធ្លោគួរឱ្យកត់សម្គាល់នោះ គឺកម្ពុជាបានធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនៃការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ ការរៀបចំប្រកួតកីឡាអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ការរៀបចំបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧នៃរដ្ឋសភា ឆ្នាំ២០២៣ និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤ ដែលបានដំណើរការប្រកបដោយជោគជ័យយ៉ាងត្រចះត្រចង់ ដោយបានលើកស្ទួយកិត្តិយសនិងកិត្យានុភាពជាតិលើឆាកអន្តរជាតិ។

ក្នុងឆ្នាំ២០២៣កន្លងទៅ សេដ្ឋកិច្ចកម្ពុជាមានកំណើនក្នុងរង្វង់ប្រមាណ**៥,៦%** សម្រាប់ឆ្នាំ២០២៤នេះ តាមការប៉ាន់ស្មាន សេដ្ឋកិច្ចកម្ពុជា អាចមានកំណើនក្នុងអត្រា**៦,៦%**។ ចំពោះទំហំពាណិជ្ជកម្មអន្តរជាតិក្នុងឆ្នាំ២០២៣ មានប្រមាណជាង **៤៧ ៨៧៧,៥១លានដុល្លារអាម៉េរិក** ចំណែកឯការនាំចេញមានប្រមាណជាង**២៣ ៤៧០,៤១លានដុល្លារអាម៉េរិក**។ អត្រាប្តូរប្រាក់មានស្ថិរភាព អតិផរណាស្ថិតក្នុងកម្រិតទាបនិងអាចគ្រប់គ្រងបាន ទុនបម្រុងអន្តរជាតិបន្តកើនឡើងដល់**២១ ២៨៥លានដុល្លារអាម៉េរិក**។ ផលិតផលក្នុងស្រុកសរុប(ផ.ស.ស.) ជាមធ្យមសម្រាប់មនុស្សម្នាក់ បានកើនឡើងពី**១ ៧៨៥ដុល្លារអាម៉េរិក** ក្នុងឆ្នាំ២០២២ ដល់ប្រមាណ**១ ៩១៧ដុល្លារអាម៉េរិក** ក្នុងឆ្នាំ២០២៣ និងត្រូវបានរំពឹងថាកើនឡើងដល់**២ ០៧១ដុល្លារអាម៉េរិក** ក្នុងឆ្នាំ២០២៤នេះ។

រាជរដ្ឋាភិបាលក៏នៅបន្តការដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការនិងកងកម្លាំងប្រដាប់អាវុធ ដោយដំឡើងប្រាក់បៀវត្សអប្បបរមាដល់ជាង**១លាន៣៥ម៉ឺនរៀល** ហើយអនុវត្តការបើកបៀវត្សបានទៀងទាត់ពេលវេលា គឺបើក២ដងក្នុងមួយខែតាមប្រព័ន្ធធនាគារ ព្រមទាំងបានដំឡើងប្រាក់សោធនជូននិវត្តជននិងជនបាត់បង់សម្បទាវិជ្ជាជីវៈ ជាអតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជន ជាពិសេសកាត់បន្ថយគម្លាតប្រាក់សោធនរវាងអ្នកចូលនិវត្តន៍ចាស់និងថ្មី។ លើសពីនេះ រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា បានដាក់ចេញនូវកម្មវិធីគោលនយោបាយអាទិភាព ចំនួន៦ ក្នុងគោលដៅលើកកម្ពស់ប្រព័ន្ធគាំពារសង្គមឱ្យកាន់តែរីកចម្រើន និងដើម្បីឆ្លើយតបសេចក្តីត្រូវការ ចាំបាច់ប្រចាំថ្ងៃរបស់ប្រជាជន ដែលរួមមាន ១-ការផ្តល់ការថែទាំសុខភាព ឆ្ពោះទៅរកកម្មវិធីគ្របដណ្តប់សុខភាពជាសកល ដោយពង្រីករបបសន្តិសុខនិងមូលនិធិសមធម៌សុខាភិបាល ដែលគិតត្រឹមត្រីមាសទី១ ឆ្នាំ២០២៤ រាជរដ្ឋាភិបាលបានពង្រីកវិសាលភាពមូលនិធិសមធម៌សុខាភិបាល ដល់គ្រួសារងាយរងហានិភ័យ សរុបជាង ៤៩ម៉ឺនគ្រួសារ គ្របសបនូវប្រជាជនប្រមាណជាង ១,៨លាននាក់ ហើយ

សមាជិក ប.ស.ស. បានកើនឡើងរហូតដល់ចំនួន **២ ១៧០ ១៦៩នាក់** ២-ការបណ្តុះបណ្តាលវិជ្ជាជីវៈនិងជំនាញបច្ចេកទេស ដល់យុវជនមកពីគ្រួសារក្រីក្រនិងគ្រួសារងាយរងហានិភ័យ នៅទូទាំងប្រទេស ដោយគិតត្រឹមត្រីមាសទី១ ឆ្នាំ២០២៤ មានយុវជនចំនួន **២៧ ៨៩៤នាក់** បានចុះឈ្មោះ និងបានបណ្តុះបណ្តាលសិស្សក្នុងវគ្គទី១ បានចំនួន ១២ ២៦៩នាក់ ក្នុងកម្មវិធីសិក្សាចំនួន៥៤៤ថ្នាក់ លើមុខជំនាញចំនួន២៤ ៣-ការធ្វើស្ថាបនូបនីយកម្មកម្មវិធីជាតិជំនួយសង្គម, ៤-ការជំរុញនិងលើកកម្ពស់ ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ៥-ការរៀបចំយន្តការសម្របសម្រួល និងកម្មវិធីហិរញ្ញប្បទាន សំដៅលើកស្ទួយ ផលិតកម្ម រកទីផ្សារ និងរក្សាលំនឹងថ្លៃកសិផលសំខាន់ៗក្នុងកម្រិតសមរម្យ និង ៦-ការដាក់ពង្រាយមន្ត្រីបច្ចេកទេស កសិកម្មនៅគ្រប់ឃុំ សង្កាត់ ដែលមានសកម្មភាពកសិកម្ម នៅទូទាំងប្រទេស ព្រមទាំងបានដាក់ចេញនូវ វិធានការគន្លឹះចំនួន៥ ដើម្បីជំរុញនិងបង្កើនល្បឿនបន្ថែមលើកិច្ចការកែទម្រង់ ក្នុងគោលដៅកែលម្អ និងឈានទៅ កសាងសមត្ថភាពនិងយន្តការស្ថាប័នរឹងមាំ ព្រមទាំងធានាឱ្យបាននូវប្រព័ន្ធរដ្ឋបាលសាធារណៈមួយប្រកបដោយ ជវភាពនិងសមិទ្ធកម្ម។

ក្នុងឆ្នាំកន្លងទៅ រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ ដោយបានជ្រើសរើសមន្ត្រីតាមនិយាមនីតិវិធីប្រតិបត្តិថ្មី ប្រកបដោយគុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព ស្របតាមពាក្យស្លោក **«អ្នកចេះ គឺជាប់»** ព្រមទាំងបានពិនិត្យឡើងវិញនិងមានការវិភាគមុខងារវិស័យអប់រំនិងប្រតិបត្តិការរដ្ឋបាលសាធារណៈ។

ក្នុងឆ្នាំសិក្សាឆ្នាំ២០២២-២០២៣ មានសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ **១៦៥ ១៣៨នាក់** ស្មើនឹង**៩៤,៥៤%** និងសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិសរុប**៩៨ ៤៦០នាក់** ស្មើនឹង**៧២,៨៩%** (បេក្ខជនជាប់និទ្ទេសA មានចំនួន**១ ៦៧៣នាក់**)។ ចំពោះកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេស ដល់យុវជនមកពីគ្រួសារក្រីក្រនិងគ្រួសារងាយរងហានិភ័យ ក្នុងគោលដៅយុវជនចំនួន **១,៥លាននាក់** កំពុងដំណើរការដោយរលូន ជាក់ស្តែង គិតត្រឹមត្រីមាសទីមួយឆ្នាំ២០២៤ មានយុវជនប្រមាណជិត**២៨ពាន់នាក់** បានចុះឈ្មោះចូលរៀន ហើយទទួលបានថវិកាឧបត្ថម្ភប្រចាំខែចំនួន**២៨ម៉ឺនរៀល**ក្នុង១ខែ។

ក្នុងការកែទម្រង់វិស័យអប់រំ រាជរដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំ ដោយអនុវត្តនីតិវិធីជ្រើសរើសសាលាគោលដៅចំនួន៥០ កម្រិតបឋមសិក្សា នៅតាមបណ្តារាជធានី ខេត្តចំនួន៩ សម្រាប់ការអនុវត្តជំហានដំបូង ដែលផ្តោតលើវិន័យ សីលធម៌ ចរិយាធម៌ ការងារស្ម័គ្រចិត្តសហគមន៍ ការចូលរួមពីសហគមន៍ សកម្មភាពសង្គម និងកីឡា។

ចំពោះការកែទម្រង់វិស័យសុខាភិបាល រាជរដ្ឋាភិបាលបាននិងកំពុងបន្តពង្រឹងសេវានៅតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក ព្រមទាំងបានបង្កើតគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យសុខាភិបាល និងដាក់ពង្រាយបុគ្គលិកសុខាភិបាល ដើម្បីធានាសេវា២៤ម៉ោងលើ២៤ម៉ោង និង៧ថ្ងៃក្នុង១សប្តាហ៍។

ក្នុងការលើកកម្ពស់ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់សង្គម និងគាំទ្រដល់ការពង្រឹងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព រាជរដ្ឋាភិបាលបានកែសម្រួលរចនាសម្ព័ន្ធអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងបង្កើតគណៈបញ្ជាការអនុវត្តយុទ្ធនាការ ហើយបានដាក់ចេញបទបញ្ជាលេខ០០១ ក្នុងការប្រយុទ្ធប្រឆាំងការប្រើប្រាស់គ្រឿងញៀនតាមក្រសួង ស្ថាប័នថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលបានបញ្ចប់ការផ្តល់អាជ្ញាបណ្ណថ្មី និងបិទទីតាំងល្បែងផ្សងសំណាងតាមមូលដ្ឋានភូមិ ឃុំ សង្កាត់ ដែលគ្មានអាជ្ញាបណ្ណ។

ក្នុងការពង្រឹងនិងលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពប្រព័ន្ធយុត្តិធម៌ រាជរដ្ឋាភិបាលបានបង្កើតអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដោយបានដាក់ចេញយុទ្ធនាការ២ គឺទី១ យុទ្ធនាការជំរុញនិងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ និងទី២ យុទ្ធនាការត្រួតពិនិត្យដោះស្រាយភាពមិនប្រក្រតី

នៅតាមតុលាការ ព្រមទាំងបានរៀបចំឡើងវិញនូវគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ និងបង្កើតគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់។ ចំពោះការកសាងច្បាប់ រាជរដ្ឋាភិបាលបានរៀបចំសេចក្តីព្រាងច្បាប់ចំនួន៨ ដើម្បីបញ្ជូនទៅស្ថាប័ននីតិប្បញ្ញត្តិ ពិនិត្យនិងអនុម័ត ហើយត្រូវបានព្រះមហាក្សត្រឡាយព្រះហស្តលេខាប្រកាសឱ្យប្រើរួចផងដែរ។

ចំពោះការកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ស្ពាន រហូតមកដល់បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលជាច្រើន ជាក់ស្តែង ក្នុងឆ្នាំ២០២៣ បានដាក់ឱ្យដំណើរការ រួមមាន (១) ផ្លូវក្រវាត់ក្រុងខ្សែទី៣ មានប្រវែង**៤៧,៦១គ.ម.** (២) ផ្លូវជាតិលេខ២ និងផ្លូវជាតិលេខ២២ មានប្រវែង**៧២,១៧គ.ម.** (៣) ផ្លូវជាតិលេខ៥ភាគខាងត្បូង មានប្រវែង**១៣៥,២៥គ.ម.** (៤) ស្ពានបេតុងខ្សែកាបកោះនរា-កោះពេជ្រ មានប្រវែង **៨២៤ម.** និង (៥) អាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ។

ចំពោះវិស័យថាមពលអគ្គិសនី ក្នុងឆ្នាំ២០២៣កន្លងទៅ ប្រភពផ្គត់ផ្គង់អគ្គិសនីរបស់កម្ពុជាសម្រេចបានជាង**១៦ ១២៣,៣៩ជីហ្គាវ៉ាត់ម៉ោង** ក្នុងនោះ ប្រភពអគ្គិសនីក្នុងស្រុក**១៣ ០៣៣,០៧ជីហ្គាវ៉ាត់ម៉ោង** ស្មើនឹង**៣៣,២២%** និងប្រភពអគ្គិសនីនាំចូលពីប្រទេសជិតខាង**៣ ០៩០,៣២ជីហ្គាវ៉ាត់ម៉ោង** ស្មើនឹង **២៩,៩៥%**។ ដោយឡែក សម្រាប់រយៈពេល៣ខែដើមឆ្នាំ២០២៤នេះ ប្រភពផ្គត់ផ្គង់អគ្គិសនីរបស់កម្ពុជាសម្រេចបានជាង**៤ ០១៨,០១ជីហ្គាវ៉ាត់ម៉ោង** ក្នុងនោះប្រភពអគ្គិសនីក្នុងស្រុក**៣ ១១៣,០៤ជីហ្គាវ៉ាត់ម៉ោង** ស្មើនឹង២៦,០២% និងប្រភពអគ្គិសនីនាំចូលពីប្រទេសជិតខាង**៩០៤,៩៧ជីហ្គាវ៉ាត់ម៉ោង** ស្មើនឹង៣៥,២៣%។

ចំពោះវិស័យកសិកម្ម ក្នុងឆ្នាំ២០២៣ បរិមាណផលិតផលស្រូវរដូវវស្សានិងស្រូវរដូវប្រាំង សម្រេចបានប្រមាណជាង**១២,៤៩លានតោន** ដែលតាមការប៉ាន់ស្មាន យើងមានអតិរេកស្រូវជិត**៧លានតោន** គិតជាអង្ករស្មើនឹង**៤,៥លានតោន** សម្រាប់បម្រើឱ្យការនាំចេញ។ កម្ពុជាបាននាំចេញកសិផលទៅក្រៅប្រទេសមានបរិមាណសរុប **៨ ៤៤៩ ៤១៤តោន** ក្នុងនោះ អង្ករបានជាង**៦៦៤ពាន់តោន** ស្រូវចំនួន**២ ៧៣០ ៨២៥តោន** និងកសិផលក្រៅពីស្រូវ អង្ករ ចំនួន**៥ ០៦២ ២៦៦តោន** ទៅកាន់ទិសដៅចំនួន**៧៨ប្រទេស**។ សម្រាប់រយៈពេល៣ខែដើមឆ្នាំ២០២៤នេះ កម្ពុជាបាននាំចេញកសិផលទៅក្រៅប្រទេសមានបរិមាណសរុប**៤ ៥៩៦ ៤៤២តោន** ក្នុងនោះ អង្ករបានជាង**១៦៦ពាន់តោន** ស្រូវចំនួន**១ ៥៥៥ ០២៥តោន** និងកសិផលក្រៅពីស្រូវ អង្ករចំនួន **២ ៨៧៤ ៩៦៦តោន** ទៅកាន់ទិសដៅចំនួន**៦៥ប្រទេស**។

ក្នុងការលើកកម្ពស់បរិយាកាសនិងការលើកទឹកចិត្តវិនិយោគ ដើម្បីជំរុញនិងបង្កើនសកម្មភាពសេដ្ឋកិច្ច ព្រមទាំងបង្កើតការងារ រាជរដ្ឋាភិបាលតាមរយៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងឆ្នាំ២០២៣កន្លងទៅ បានអនុញ្ញាតឱ្យក្រុមហ៊ុនវិនិយោគលើគម្រោងសរុបចំនួន**២៦៨** ក្នុងនោះ គម្រោងក្រៅតំបន់សេដ្ឋកិច្ចពិសេស**១៧៦** គម្រោងពង្រីកផលិតកម្ម**២១** និងគម្រោងក្នុងតំបន់សេដ្ឋកិច្ចពិសេស**៧១** ដែលមានទុនវិនិយោគសរុប **៤ ៩២៧ ៥៤៩ ២២៤ដុល្លារអាម៉េរិក** និងអាចបង្កើតការងារបានជាង**៣០៧ ៥៥៣កន្លែង**។ ដោយឡែក សម្រាប់រយៈពេល៣ខែដើមឆ្នាំ២០២៤នេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានអនុញ្ញាតឱ្យក្រុមហ៊ុនវិនិយោគលើគម្រោងចំនួន**១០៦** ក្នុងនោះ គម្រោងក្រៅតំបន់សេដ្ឋកិច្ចពិសេស**៧៣** និងគម្រោងក្នុងតំបន់សេដ្ឋកិច្ចពិសេស**៣៣** ដែលមានទុនវិនិយោគសរុបប្រមាណ**២,២៣ពាន់លានដុល្លារអាម៉េរិក** និងអាចបង្កើតការងារបានជាង**១០៧ពាន់កន្លែង**។

ចំពោះវិស័យឧស្សាហកម្ម មានសហគ្រាស គ្រឹះស្ថានដែលចុះបញ្ជីក្នុងឆ្នាំ២០២៣ បានកើនឡើងដល់ចំនួន**៤៣ ៧៥១** ដែលស្រូបកម្លាំងពលកម្មសរុបប្រមាណ**១,៨លាននាក់**ទូទាំងប្រទេស ខណៈក្នុងរយៈពេល៣ខែដើមឆ្នាំ២០២៤ សហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជី មានចំនួន**៣ ០៤៨** ដែលស្រូបកម្លាំងពលកម្មសរុបប្រមាណ**១៤០ ៥២៤នាក់**។ ដោយឡែក ប្រាក់ឈ្នួលអប្បបរមារបស់កម្មករ និយោជិត ផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប ក៏ត្រូវបានដំឡើងដល់**២០៤ដុល្លារអាម៉េរិក**

ប្តូររួមនឹងអត្ថប្រយោជន៍ជាកាតព្វកិច្ចផ្សេងទៀត ក៏ដូចជាការបន្តទទួលបាននូវអត្ថប្រយោជន៍ផ្សេងៗទៀតពីការអនុវត្តគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាល។ ជាមួយគ្នានេះ ក្នុងរយៈពេល៦ខែដំបូងរបស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា បានពង្រីករបបសន្តិសុខសង្គម និងមូលនិធិសមធម៌សុខាភិបាល គ្របដណ្តប់ប្រជាពលរដ្ឋចំនួន**៦,៨លាននាក់** ក្នុងនោះមានសមាជិកបេឡាជាតិសន្តិសុខសង្គម(ប.ស.ស.) ទាំងរបបកាតព្វកិច្ចនិងរបបស្ម័គ្រចិត្ត មានចំនួន**២,២លាននាក់** មូលនិធិសមធម៌សម្រាប់ប្រជាជននៃគ្រួសារងាយរងហានិភ័យ មានចំនួន**១,៨លាននាក់** មូលនិធិសមធម៌សម្រាប់ប្រជាជនគ្រួសារក្រីក្រ(ក្រ១និងក្រ២) មានចំនួន**២,៨លាននាក់** និងបានពង្រីកការគ្របដណ្តប់របបសន្តិសុខសង្គមជូនដល់បុគ្គលស្វ័យនិយោជន៍ជាង**១៥ម៉ឺននាក់** និងអ្នកក្នុងបន្ទុកសមាជិកប.ស.ស. ជិត**៤ម៉ឺននាក់**។

ចំពោះវិស័យទេសចរណ៍ ភ្ញៀវទេសចរអន្តរជាតិចូលមកព្រះរាជាណាចក្រកម្ពុជា ក្នុងឆ្នាំ២០២៣ មានចំនួនប្រមាណជាង**៥,៤៥លាននាក់** កើនឡើងប្រមាណ**១៣៩,៥០%** និងភ្ញៀវទេសចរជាតិមានចំនួនប្រមាណជាង**១៨,៧៤លាននាក់** កើនឡើងប្រមាណ**៣៤,៥០%**។ សម្រាប់រយៈពេល២ខែដើមឆ្នាំ២០២៤នេះ ភ្ញៀវទេសចរអន្តរជាតិដែលបានចូលមកព្រះរាជាណាចក្រកម្ពុជា មានចំនួនប្រមាណជាង**៩៩ម៉ឺននាក់** កើនឡើងប្រមាណ**១៨%**ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣ ខណៈភ្ញៀវទេសចរជាតិមានចំនួនប្រមាណជាង**២,៧៧លាននាក់**។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលក៏បាននិងកំពុងបន្តពង្រឹងការអភិរក្សនិងអភិវឌ្ឍវិស័យវប្បធម៌ ទាំងបេតិកភណ្ឌរូបីនិងអរូបី ព្រមទាំងជំរុញទេសចរណ៍វប្បធម៌ជាគោលនយោបាយទាក់ទាញទេសចរ ដើម្បីរួមចំណែកដល់ការជំរុញកំណើនសេដ្ឋកិច្ចជាតិ។

**សម្តេចព្រះមហាសង្ឃរាជ សម្តេចព្រះសង្ឃនាយក សម្តេចព្រះរាជាគណៈ ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ សម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី ជាទីមេត្រី បងប្អូនជនរួមជាតិទាំងអស់ជាទីស្នេហា!**

រាល់សមិទ្ធផលដែលរាជរដ្ឋាភិបាលសម្រេចបានកន្លងទៅនេះ គឺអាស្រ័យដោយមានការដឹកនាំខាងនយោបាយដ៏ត្រឹមត្រូវ ប្រកបដោយឆន្ទៈមោះមុត មានការចូលរួមគាំទ្រថ្នាក់ដឹកនាំ និងប្រជាពលរដ្ឋទូទាំងប្រទេស ព្រមជាមួយនឹងការជួយឧបត្ថម្ភគាំទ្រដោយចិត្តស្មោះសរពីបណ្តាប្រទេសជាមិត្ត ដៃគូអភិវឌ្ឍ និងសហគមន៍អន្តរជាតិ។ រាជរដ្ឋាភិបាលនឹងបន្ត ធ្វើការកែទម្រង់ស៊ីជម្រៅ ព្រមទាំងប្រកាន់ខ្ជាប់អភិក្រម **«ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់»** ក្នុងនោះមានការបន្តពង្រឹងអភិបាលកិច្ចល្អ តាមរយៈការពង្រឹងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការបន្តកែទម្រង់លើវិស័យសំខាន់ៗ ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ការអភិវឌ្ឍធនធានមនុស្ស ការជំរុញបរិវត្តកម្មឌីជីថល ការលើកកម្ពស់ប្រព័ន្ធគាំពារសង្គម ការលើកកម្ពស់គុណភាពសេវាសុខាភិបាល ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សំណង់ ផ្លូវ ស្ពាន និងធារាសាស្ត្រ ការបង្កើនប្រភពថាមពលអគ្គិសនី ការអភិវឌ្ឍវិស័យឧស្សាហកម្ម សិប្បកម្ម ពាណិជ្ជកម្ម ទេសចរណ៍ និងកសិកម្ម ឱ្យកាន់តែរីកចម្រើនឥតឈប់ឈរថែមទៀត។ ក្នុងន័យនេះ រាជរដ្ឋាភិបាលសូមអំពាវនាវដល់គ្រប់តួអង្គពាក់ព័ន្ធទាំងអស់ផ្តល់នូវការគាំទ្រ និងចូលរួមអនុវត្តដោយសកម្មក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ចំពោះជោគវាសនារបស់ប្រទេសជាតិ ដោយឈរលើគោលការណ៍តម្កល់នូវផលប្រយោជន៍ជាតិនិងប្រជាជនជាធំ ដើម្បីជម្នះបាននូវបញ្ហាប្រឈម ហានិភ័យ និងឧបសគ្គទាំងឡាយ សំដៅបន្តដឹកនាំនាវាកម្ពុជារក្សាការពារបានសុខសន្តិភាពយូរអង្វែង មានវឌ្ឍនភាព វិបុលភាព និងយុត្តិធម៌សង្គម។

ឆ្លៀតក្នុងឱកាសនេះ ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា ខ្ញុំ សូមបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការការពាររដ្ឋធម្មនុញ្ញ ការពាររបបរាជានិយម ស្របតាមបាវចនា **«ជាតិ សាសនា ព្រះមហាក្សត្រ»** និងការពាររាល់សមិទ្ធផលដែលរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាទាំងមូលសម្រេចបាននាពេលកន្លងមកឱ្យបានគង់វង្ស មិនឱ្យបុគ្គលណា ក្រុមណា ឬបរទេសណាមកបំផ្លាញទៅវិញបានឡើយ។ ទន្ទឹមនេះ រាជរដ្ឋាភិបាល

ប្តេជ្ញាបន្តរួបរួមសាមគ្គីគ្នាជាធ្លុងមួយក្រោមដំបូលរដ្ឋធម្មនុញ្ញ និងម្លប់ដ៏ត្រជាក់នៃអង្គព្រះមហាក្សត្រជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដើម្បីសម្រេចបានសមិទ្ធផលថ្មីៗទៀតក្នុងការកសាងនិងការពារមាតុភូមិជាទីស្នេហានៃយើង។

**សម្តេចព្រះមហាសង្ឃរាជ សម្តេចព្រះសង្ឃនាយក សម្តេចព្រះរាជាគណៈ ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ សម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី ជាទីមេត្រី បងប្អូនជនរួមជាតិទាំងអស់ជាទីស្នេហា!**

ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំរោង ឆស័ក ព.ស.២៥៦៨នេះ ទូលព្រះបង្គំជាខ្ញុំ ក្នុងនាមរាជរដ្ឋាភិបាល ព្រមទាំងមន្ត្រីរាជការ កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និងបងប្អូនជនរួមជាតិទាំងអស់ សូមលំឱនកាយវាចាចិត្ត គោរពបួងសួងដល់គុណបុណ្យព្រះរតនត្រ័យកែវទាំងបី វត្ថុសក្តិសិទ្ធិក្នុងលោក ទេវតាឆ្នាំថ្មី ព្រះនាម **មហោទរាទេវី** សូមប្រោះព្រំសព្ទសាធុការពរ បវរមហាប្រសើរ ថ្វាយចំពោះ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គមានព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ព្រះរាជសុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា ដើម្បីបានគង់ប្រថាប់នៅក្នុងព្រះបរមសិរីរាជសម្បត្តិ ជាម្លប់ដ៏ត្រជាក់នៃប្រជាជនខ្មែរ ជាកូន ចៅ ចៅទួត ជានិច្ចនិរន្តរ៍តរៀងទៅ។

ក្នុងឱកាសដ៏មហានក្ខត្តឫក្សនេះដែរ ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមទូលព្រះបង្គំ ខ្ញុំព្រះករុណា សូមប្រគេនព្រះពរចំពោះសម្តេចព្រះមហាសង្ឃរាជ សម្តេចព្រះសង្ឃនាយក សម្តេចព្រះរាជាគណៈ និងព្រះសង្ឃគ្រប់ព្រះអង្គ សូមមានព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា មានព្រះសុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា ដើម្បីបានគង់ប្រថាប់ជាម្លប់របស់ពុទ្ធបរិស័ទក្នុងព្រះរាជាណាចក្រកម្ពុជា យូរអង្វែងតទៅ។

សូមជូនពរដល់ជនរួមជាតិខ្មែរគ្រប់រូបដែលកំពុងរស់នៅក្នុងនិងក្រៅប្រទេស មន្ត្រីរាជការ នាយទាហាន ពលទាហាននៃកងយោធពលខេមរភូមិន្ទ ដែលបាននិងកំពុងបំពេញភារកិច្ចការពារអធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា និងកំពុងបំពេញបេសកកម្មរក្សាសន្តិភាពនិងមនុស្សធម៌នៅក្រៅប្រទេស នាយនគរបាល ពលនគរបាលដែលបាននិងកំពុងរួមចំណែកការពារបូរណភាពទឹកដីនិងថែរក្សាការពារសន្តិភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនៃមាតុភូមិ លោកគ្រូ អ្នកគ្រូ គ្រូពេទ្យ ក្មួយៗសិស្សានុសិស្ស និស្សិត យុវជន កម្មករ កសិករ និយោជិត ធុរជន និងវិនិយោគិនដែលកំពុងប្រកបធុរកិច្ចនៅលើទឹកដីកម្ពុជា សូមទទួលបាននូវភាពជោគជ័យ សិរីសួស្តី ជ័យមង្គល និងវិបុលសុខគ្រប់ប្រការ។

សូមទេវតាឆ្នាំថ្មី ព្រះនាម **មហោទរាទេវី** អភិបាលគ្រប់គ្រង ជួយបីបាច់ថែរក្សាគាំពារ និងប្រសិទ្ធពរជ័យដល់ប្រជាជនខ្មែរគ្រប់រូប ឱ្យមានសមានចិត្តជាកុសល យោគយល់គ្នា រួបរួមសាមគ្គីគ្នាជាមហាគ្រួសារខ្មែរតែមួយ នៅលើទឹកដីមាតុភូមិអង្គរជាទីស្នេហា ដោយសេចក្តីសុខក្សេមក្សាន្ត និងប្រកបដោយកិត្តិយស សេចក្តីថ្លៃថ្នូរ ក្នុងឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ អព្យាក្រឹត និងវឌ្ឍនភាពសង្គមតរៀងទៅ។

**សូមអរព្រះគុណនិងអរគុណ!**

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែមេសា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**